# JOINT PRESS RELEASE

## World Breastfeeding Week 2021: A Shared Responsibility
***Let's invest in breastfeeding for a healthier, more sustainable Cambodia***

August 1st, 2021: The Scaling Up Nutrition Civil Society Alliance in Cambodia's members (Helen Keller, Alive & Thrive, and World Vision International (WVI)-Cambodia), in partnership with the National Nutrition Program, GIZ, MUSUFO, USAID, RTI and UNICEF, would like to announce the annual celebration of World Breastfeeding Week in Cambodia for 2021, under the theme '*Protecting breastfeeding: A shared responsibility'*. World Breastfeeding Week is celebrated in more than 120 countries around the globe to raise awareness about the importance of breastfeeding for the survival, health, and well-being of mothers and children, and for the benefit of society at large. Although individual breastfeeding behavior is important, this year's *World Breastfeeding Week* calls upon families, communities, governments, and the whole of society to invest in and support breastfeeding for a healthier and more sustainable world.

Though World Breastfeeding Week takes place from August 1st to 7th, efforts to protect, promote, and support breastfeeding in Cambodia continue year-round. In line with restrictions aimed at preventing the spread of COVID-19, this year's celebration will take place mainly online, including dissemination of videos, live talk shows, and quizzes across social media. In addition to pregnant women and breastfeeding mothers, these celebrations will target fathers, grandparents, caregivers, health workers, community leaders and other relevant members of the community who can share experiences and celebrate the power and joy of breastfeeding.

From 2000 to 2010, Cambodia's exclusive breastfeeding rate – the proportion of babies fed only with breastmilk from birth to six months of age in line with WHO recommendations – increased dramatically, from 11% to 74%. Since 2001, the Ministry of Health's National Nutrition Program, in collaboration with key nutrition partners at that time (WHO, UNICEF, Helen Keller), has led celebrations of the annual and global World Breastfeeding Week. Following the remarkable progress, World Breastfeeding Week celebrations in Cambodia ceased in 2010, based on the assumption that the public was already aware of the importance of breastfeeding. However, new data from 2014 revealed that the exclusive breastfeeding rate had fallen and that the use of formula milk was on the rise, endangering child health and survival and costing families and the economy. As a result, World Breastfeeding Week was revitalized in Cambodia by the National Nutrition Program, Helen Keller, FHI360, UNICEF, WVI-Cambodia, Save the Children, and other partners starting in 2015. The COVID-19 pandemic has further emphasized the need to continue supporting and investing in breastfeeding. Separation of mothers and babies, disruptions to health services including breastfeeding counseling and support, and unethical marketing of formula milk to the public during the pandemic has had a potentially negative impact on breastfeeding practices. The need to invest in and support breastfeeding has never been greater.

Globally, nearly 600,000 children and 100,000 mothers die each year due to poor breastfeeding rates.[1] By improving breastfeeding rates, more than 1,000 deaths and 5 million cases of diarrhea among children under two could be prevented in Cambodia each year, along with 255 maternal deaths due to breast and ovarian cancer and Type II diabetes. Scaling up breastfeeding would also save Cambodia's health system 5 million US dollars per year and save Cambodian families over 107 million US dollars per year due to the cost of purchasing formula milk for non-breastfed babies. The Ministry of Health, along with other partners, calls for a whole of society approach to create an environment that enables breastfeeding and supports breastfeeding mothers.

Unethical marketing and promotion of formula milk is a major barrier to improving breastfeeding rates. That's why during this year's World Breastfeeding Week, to compliment the current monitoring system, the SUN CSA Cambodia is launching a new online system[1] for reporting the violations against Sub-Decree 133 on the Marketing of Products for Infant and Young Child Feeding[2], which will be led by WVI-Cambodia. This online reporting system will allow health professionals, civil society organizations, and the public to report the violations in a simple and easy way. This online system will also allow Government officials to receive additional quality information and monitor the trends and patterns in implementation of Sub-degree 133. This is an effort to prevent illegal promotion and marketing of infant and young child feeding products, through advertisements, displays, discounts, prizes, or gifts, providing samples, distributing information materials, along with other promotional tactics.

World Breastfeeding Week 2021 under the theme "*Protecting Breastfeeding: A Shared Responsibility"* will bring together all relevant stakeholders at the national and sub-national levels to truly engage breastfeeding mothers and their community of supporters (fathers, grandparents, other family members) and the whole society to remind them about the importance of protecting, promoting, and supporting breastfeeding to ensure a healthier, more prosperous Cambodia.

- To understand more about sub-decree 133 and Joint Prakas on Marketing of Product for Infant and Young Child Feeding: *https://bit.ly/3zS8Q8e*
- Roles and responsibilities of Health Facilities in line with sub-decree 133: *https://bit.ly/3icCFuv*
- Online System for reporting violations of sub-decree 133: *https://bit.ly/violationsub133*
- How to report violations online: *https://bit.ly/violationsub133*

[1] Walters D, Phan L, Mathisen R. The Cost of Not Breastfeeding: Global Results from a New Tool. *Health Policy and Planning*. 2019 June 24. Available from https://doi.org/10.1093/heapol/czz050

**Note to Editors:**

**Helen Keller International** is a global health organization dedicated to eliminating preventable vision loss, malnutrition, and diseases of poverty. Co-founded by Helen Keller — and guided by her fierce optimism and belief in human potential — the organization delivers life-changing health solutions to vulnerable families in places where the need is great but access to care is limited. In the U.S., Africa, and Asia, Helen Keller's proven, science-based programs empower people to create opportunities in their own lives and build lasting change. Helen Keller overcame tremendous obstacles to her health and wellbeing – and helped millions of others to do the same. Guided by her remarkable legacy, Helen Keller partners with host governments, development partners, civil society organizations and communities that are striving to overcome longstanding cycles of poverty.
**For more information:** Helen Keller International - Continuing Her Work (hki.org)

**World Vision International** is a Christian relief, development and advocacy organisation dedicated to working with children, families and communities to overcome poverty and injustice. World Vision serves all people, regardless of religion, race, ethnicity or gender. World Vision commenced work in Cambodia in 1970. Working closely with Government ministries, local partners and community groups, we collaborate with communities to improve the lives of Cambodian children, especially most vulnerable children, in three key areas; integrated nutrition, education, and child protection and participation. World Vision works across 15 provinces and Phnom Penh City. World Vision implements long-term Area Programmes in nine provinces and Phnom Penh (these are Banteay Meanchey, Battambang, Kampong Chhnang, Kampong Speu, Kandal, Kampong Thom, Preah Vihear, Siem Reap,Takeo). Grant funded projects extend coverage to include Kep, Kampong Cham, Preah Sihanouk, Prey Veng, Pursat and Svay Rieng.
**For more information:** https://www.wvi.org/publications/cambodia

**Alive & Thrive** is a global nutrition initiative to save lives, prevent illness, and ensure healthy growth of mothers and children. From 2009-2014, A&T demonstrated that rapid improvements in infant and young child feeding (IYCF) are possible in settings as diverse as Ethiopia, Bangladesh, and Viet Nam. In 2014, A&T began working in Burkina Faso, India, Nigeria, and throughout the Southeast Asia region, expanding its scope to include maternal and adolescent nutrition, and using agriculture and social protection programs as delivery mechanisms for maternal, infant, and young child nutrition (MIYCN). Currently, Alive & Thrive is leveraging its robust network and knowledge base to strengthen systems and build capacity in these and other countries across Africa and Asia, and disseminate innovations, tools, and lessons worldwide. Alive & Thrive is managed by FHI 360 with funding from the Bill & Melinda Gates Foundation, Government of Ireland and other donors.
**For more information**: https://www.aliveandthrive.org/en

***For more information, please contact:***


- Ponlork Van, *Communications Coordinator, Helen Keller International*
  Tel: +855 89 55 57 02, email: PVan@hki.org
- Sokhen Sun, *Senior Public Engagement Specialist*
  Tel: +855 10 90 64 09, email: sokhen_sun@wvi.org
- Chin Sedtha, Program Manager, Alive & Thrive / FHI360,
  *Tel: +855 12 81 99 15, email: CSedtha@fhi360.org*

# សេចក្តីប្រកាសព័ត៌មានរួម

## ទិវាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ២០២១៖ទំនួលខុសត្រូវទាំងអស់គ្នា

## តោះយើងវិនិយោគក្នុងការបំបៅកូនដោយទឹកដោះម្តាយ ដើម្បីសុខុមាលភាព និងនិរន្តន៍ភាពប្រសើរឡើងរបស់កម្ពុជា

**ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១**

សមាជិកនៃសម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភកម្ពុជា (អង្គការ Helen Keller អង្គការ Alive & Thrive និង អង្គការទស្សនៈពិភពលោកអន្តរជាតិ-កម្ពុជា) ក្នុងភាពជាដៃគូជាមួយកម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិ អង្គការ GIZ, MUSUFO, USAID, RTI និង អង្គការយូនីសេហ្វសូមប្រកាសទិវាសប្តាហ៍ពិភពលោក បំបៅកូនដោយទឹកដោះម្តាយនៅកម្ពុជាសម្រាប់ ឆ្នាំ២០២១ ក្រោមប្រធានបទ«***យើងទាំងអស់រួមគ្នា គាំពារនិងគាំទ្រការបំបៅកូនដោយទឹកដោះម្តាយ***»។ ទិវានេះត្រូវបានប្រារព្ធធ្វើឡើងនៅជាង១២០ប្រទេសទូទាំងពិភពលោក ដើម្បីលើកកម្ពស់ការយល់ដឹងពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះម្តាយសម្រាប់ការរស់រាន សុខភាព និងសុខុមាលភាពរបស់ម្តាយនិងកូនៗរបស់ពួកគាត់ ក៏ដូចជាប្រយោជន៍សម្រាប់សង្គមជាតិទាំងមូល។ បើទោះបីជាការបំបៅកូនជារឿងរបស់បុគ្គលជាម្តាយយ៉ាងណាក្តី ប៉ុន្តែនៅឆ្នាំនេះទិវាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ២០២១ សូមអំពាវនាវដល់គ្រួសារ សហគមន៍ រដ្ឋាភិបាល និងសង្គមទាំងមូលរួមគ្នាវិនិយោគ និងគាំទ្រការបំបៅកូនដោយទឹកដោះម្តាយ សម្រាប់ពិភពលោកមួយដែលមានសុខភាព និងនិរន្តន៍ភាពជាងមុន។

ទោះបីជាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយប្រារព្ធធ្វើឡើងតែក្នុងរយៈពេលមួយសប្តាហ៍ពោល គឺពីថ្ងៃទី១ ដល់ថ្ងៃទី៧ ខែសីហា ក្តី កិច្ចខិតខំប្រឹងប្រែងដើម្បីការពារ លើកកម្ពស់ និងគាំទ្រដល់ការ បំបៅកូនដោយទឹកដោះម្តាយនៅក្នុងប្រទេសកម្ពុជានៅតែបន្តធ្វើពេញមួយឆ្នាំ។ ដោយគោរពទៅតាមការណែ នាំក្នុងការទប់ស្កាត់ការរីករាលនៃជំងឺកូវីដ-១៩ ការប្រារព្ធទិវាបំបៅកូនដោយទឹកដោះម្តាយ នៅឆ្នាំនេះនឹងធ្វើឡើងតាមអនឡាញដែលក្នុងនោះការចែកចាយវីដេអូ ការជជែកពិភាក្សាផ្សាយផ្ទាល់ និងការឆ្លើយសំណួរតាមបណ្តាញសង្គមជាដើម។ ក្រៅពីស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលកំពុងបំបៅកូនដោយទឹកដោះ ឪពុក ជីដូនជីតា អាណាព្យាបាល បុគ្គលិកសុខាភិបាល អ្នកដឹកនាំសហគមន៍ និងសមាជិកពាក់ព័ន្ធដទៃទៀតក្នុងសហគមន៍ដែលអាចចែករំលែកបទពិសោធន៍និងប្រើប្រាស់សិទ្ធិអំណាច និងពេញចិត្តចំពោះការបំបៅកូនដោយទឹកដោះម្តាយ នឹងក្លាយជាក្រុមគោលដៅនៃការផ្សព្វផ្សាយនៃកម្មវិធីផ្សាយតាមអនឡាញទាំងនេះ។

ចាប់តាំងពីឆ្នាំ២០០០ដល់ឆ្នាំ២០១០ អត្រានៃការបំបៅកូនដោយទឹកដោះតែមួយមុខនៅប្រទេសកម្ពុជា(សមាមាត្រនៃទារកដែលបៅទឹកដោះម្តាយតែមួយមុខចាប់ពីកើតរហូតដល់អាយុ៦ខែស្របទៅតាមការណែនាំរបស់អង្គការសុខភាពពិភពលោក) កើនឡើងយ៉ាងខ្លាំងពោលគឺចាប់ពី១១ភាគរយរហូតដល់៧៤ភាគរយ។ ចាប់ពីឆ្នាំ២០០១ កម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល ក្នុងកិច្ចសហប្រតិបត្តិការជាមួយដៃគូអាហារូបត្ថម្ភសំខាន់ៗនាពេលនោះ(អង្គការសុខភាពពិភពលោក អង្គការយូនីសេហ្វ និងអង្គការHelen Keller) ប្រារព្ធសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយជារៀងរាល់ឆ្នាំ។ ដោយមើលឃើញពីកំណើននៃការបំបៅកូនដោយទឹកដោះម្តាយមានការកើនឡើងគួរឱ្យកត់សម្គាល់ ការប្រារព្ធសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ ត្រូវបានបញ្ឈប់នៅឆ្នាំ២០១០ ដោយយោងទៅតាមការសន្និដ្ឋាននាពេលនោះថាសាធារណជនមានការយល់ដឹងទូលំទូលាយពីសារៈសំខាន់នៃការបំបៅកូនដោយទឹកដោះហើយ។ ប៉ុន្តែរបាយការណ៍សិក្សាថ្មីមួយដែលចេញនៅឆ្នាំ២០១៤ បែរជាបង្ហាញថាការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខបានធ្លាក់ចុះ ហើយការប្រើប្រាស់ផលិតផលទឹកដោះគោមានការកើនឡើងទៅវិញ ដែលបង្កនូវគ្រោះថ្នាក់ដល់សុខភាពនិងការរស់រានមានជីវិតរបស់កុមារ ក៏ដូចជាធ្វើឱ្យប៉ះពាល់ដល់ការចំណាយនិងសេដ្ឋកិច្ចគ្រួសារផងដែរ។ ហេតុនេះហើយទើបទិវាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយនៅប្រទេសកម្ពុជាត្រូវបានប្រារព្ធ ឡើងវិញចាប់ពីឆ្នាំ២០១៥ ដោយមានការចូលរួមពីកម្មវិធីអាហារូបត្ថម្ភថ្នាក់ជាតិ

អង្គការHelen Keller អង្គការFHI360 អង្គការយូនីសេហ្វ អង្គការទស្សនៈពិភពលោកអន្តរជាតិ-កម្ពុជា និងអង្គការសង្គ្រោះកុមារ។ ការផ្ទុះឡើងនូវជំងឺកូវីដ១៩ បានជំរុញឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀតក្នុងការគាំទ្រ និងវិនិយោគលើការបំបៅដោះកូនដោយទឹកដោះម្តាយ។ ការបំបែកម្តាយនិងកូន ការរំខានពីការទទួលបានសេវាសុខភាពដូចជាការប្រឹក្សាពីការបំបៅកូន និងការផ្សព្វផ្សាយពីផលិតផលទឹកដោះគោដោយគ្មានសីលធម៌ ក្នុងអំឡុងពេលដែលជំងឺរីករាតត្បាតសកល កំពុងជះឥទ្ធិពលជាអវិជ្ជមានដល់ការអនុវត្តការបំបៅដោះកូនដោយទឹកដោះម្តាយ។ តម្រូវការនៃការវិនិយោគ និងគាំទ្រដល់ការបំបៅកូនដោយទឹកដោះម្តាយកាន់តែមានភាពធំធេងថែម ទៀត។

នៅទូទាំងពិភពលោកទាំងមូល កុមារជិត៦០០ ០០០នាក់ និងម្តាយ១០០ ០០០ នាក់ បានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារតែអត្រានៃការបំបៅកូនដោយទឹកដោះម្តាយមានកម្រិតទាប[1]។ ដោយធ្វើឱ្យប្រសើរឡើងនូវអត្រានៃការបំបៅកូនដោយទឹកដោះម្តាយ មរណៈភាពចំនួន១០០០នាក់ និងជំងឺរាគរូសចំនួន៥លានករណីលើកុមារអាយុក្រោម២ឆ្នាំ រួមទាំងមរណៈភាពរបស់មាតាចំនួន២៥៥នាក់ដោយសារជំងឺមហារីកសុដន់ ក្រពេញអូវែ និងទឹកនោមផ្អែមកម្រិតII នៅប្រទេសកម្ពុជា អាចត្រូវបានទប់ស្កាត់ជារៀងរាល់ឆ្នាំ។ ការបង្កើនការបំបៅដៅកូនដោយទឹកដោះម្តាយនឹងជួយសន្សំសំចៃដល់ប្រព័ន្ធសុខាភិបាលប្រទេសកម្ពុជារហូតដល់៥លានដុល្លា និងជួយសន្សំគ្រួសារក្នុងប្រទេសកម្ពុជារហូតដល់ជាង១០៧លានដុល្លាក្នុងមួយឆ្នាំដែលជាតម្លៃនៃការទិញផលិតផលទឹកដោះគោសម្រាប់ទារកដែលមិនបៅទឹកដោះម្តាយ។ ក្រសួងសុខាភិបាល និងអង្គការដៃគូរ អំពាវនាវឱ្យមានយុទ្ធសាស្ត្រសង្គមទាំងមូល ដើម្បីបង្កើតនូវបរិយាកាសដែលជួយដល់ការបំបៅកូនដោយទឹកដោះម្តាយ ក៏ដូចជាគាំទ្រដល់ស្ត្រីដែលជាម្តាយដែលកំពុងបំបៅដោះកូនផងដែរ។

ការធ្វើទីផ្សារនិងការផ្សព្វផ្សាយដោយគ្មានក្រមសីលធម៌ពីផលិតផលទឹកដោះគោ ជាឧបសគ្គយ៉ាងធំដែលរារាំងដល់អត្រានៃការបំបៅកូនដោយទឹកដោះម្តាយ។ ដោយមើលឃើញពីបញ្ហានេះទើបក្នុងអំឡុងទិវាសប្តាហ៍ពិភព លោកបំបៅកូនដោយទឹកដោះម្តាយនាឆ្នាំនេះ សម្ព័ន្ធអង្គការសង្គមស៊ីវិលដើម្បីអាហារូបត្ថម្ភកម្ពុជា នឹងដាក់ឱ្យ ដំណើរការនូវប្រព័ន្ធអនឡាញមួយដែលបំពេញបន្ថែមលើប្រព័ន្ធដែលមានស្រាប់ សម្រាប់រាយការណ៍ពីការ រំលោភបំពានអនុក្រឹត្យ១៣៣ដែលចែងពីការធ្វើទីផ្សារផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ។ ប្រព័ន្ធរាយការណ៍នេះត្រូវបានបង្កើតឡើងដោយមានការដឹកនាំនិងសម្របសម្រួលដោយអង្គការទស្សនៈពិភពលោក។ ប្រព័ន្ធរាយការណ៍តាមអនឡាញនេះ នឹងអនុញ្ញាតឱ្យអ្នកជំនាញសុខាភិបាល អង្គការសង្គមស៊ីវិល និង សាធារណៈជនទូទៅរាយការណ៍ពីការរំលោភបំពានអនុក្រឹត្យ១៣៣តាមវិធីសាមញ្ញនិងងាយស្រួលមួយ។ ប្រព័ន្ធរាយការណ៍តាមអនឡាញនេះ ក៏នឹងអនុញ្ញាតឱ្យមន្ត្រីរដ្ឋាភិបាលទទួលបាននូវព័ត៌មានប្រកបដោយគុណភាព និងអាចតាមដានពីនិន្នាការនិងបរិបទ ក្នុងការអនុវត្តអនុក្រឹត្យ១៣៣ផងដែរ។ ការបង្កើតប្រព័ន្ធនេះជាកិច្ចខិតខំប្រឹងប្រែងមួយក្នុងការទប់ស្កាត់ការផ្សព្វផ្សាយ និងការធ្វើទីផ្សារដោយខុសច្បាប់ចំពោះផលិតផលសម្រាប់ទារកនិងកុមារបរិភោគ តាមរយៈការផ្សព្វផ្សាយ ការតាំងបង្ហាញ ការបញ្ចុះតម្លៃ រង្វាន់ឬអំណោយ ការឱ្យសាកល្បង ការចែកចាយព័ត៌មាន រួមទាំងយុទ្ធសាស្ត្រនៃការផ្សព្វផ្សាយតាមរូបភាពដទៃទៀត។

ទិវាសប្តាហ៍ពិភពលោកបំបៅកូនដោយទឹកដោះម្តាយ២០២១ ក្រោមប្រធានបទ« យើងទាំងអស់រួមគ្នាគាំពារ និងគាំទ្រការបំបៅកូនដោយទឹកដោះម្តាយ» នឹងនាំយកភាគីពាក់ព័ន្ធទាំងអស់ទាំងថ្នាក់ជាតិនិងក្រោមជាតិ ដើម្បីចូលរួមដោយពិតប្រាកដជាមួយម្តាយដែលបំបៅកូនដោយទឹកដោះ និងសហគមន៍នៃអ្នកគាំទ្ររបស់ពួកគេ (ឪពុក ជីដូនជីតា និងសមាជិកដទៃទៀតក្នុងគ្រួសារ) រួមទាំងសង្គមជាតិទាំងមូល ដោយរំលឹកពួកគេពីសារៈសំខាន់នៃការការពារ ការលើកកម្ពស់ ការគាំទ្រ ការបំបៅកូនដោយទឹកដោះម្តាយ ដើម្បីប្រាកដថាកម្ពុជាជាសង្គមដែលមានសុខភាពល្អ និងរីកចម្រើនថែមទៀត៕

- ដើម្បីស្វែងយល់បន្ថែមពីអនុក្រឹត្យ១៣៣ និងសេចក្តីប្រកាសរួមអន្តរក្រសួងស្តីការផ្សព្វផ្សាយលក់ផលិតផលសម្រាប់ចិញ្ចឹមទារកនិងកុមារ សូមចូលទៅកាន់ https://bit.ly/3zS8Q8e

[1] Walters D, Phan L, Mathisen R. The Cost of Not Breastfeeding: Global Results from a New Tool. *Health Policy and Planning*. 2019 June 24. Available from https://doi.org/10.1093/heapol/czz050

- តួនាទី និងការទទួលខុសត្រូវរបស់អ្នកផ្តល់សេវាសុខាភិបាលដែលស្របទៅតាមអនុក្រឹត្យ១៣៣ សូមចូលទៅកាន់ *https://bit.ly/3icCFuv*
- ប្រព័ន្ធសម្រាប់រាយការណ៍ពីការរំលោភបំពានលើអនុក្រឹត្យ១៣៣ សូមចូលទៅកាន់ *https://bit.ly/violationsub133*

## សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសេចក្តីប្រកាសព័ត៌មានរួមនេះសូមទាក់ទង៖


- លោក វ៉ាន់ ពន្លក *អ្នកសម្របសម្រួលទំនាក់ទំនងព័ត៌មាន អង្គការ ហេឡែន ខេលល័រ អន្តរជាតិ*
  Tel: +855 89 55 57 02, email: PVan@hki.org
- លោក ស៊ុន សុខេន *អ្នកជំនាញជាន់ខ្ពស់កិច្ចការទំនាក់ទំនងសាធារណៈ អង្គការទស្សនៈពិភពលោកកម្ពុជា*
  Tel: +855 10 90 64 09, email: sokhen_sun@wvi.org
- លោកស្រី ជិន សេដ្ឋា *ប្រធានកម្មវិធី Alive & Thrive (A&T) នៃអង្គការ FHI 360*
  Tel: +855 12 81 99 15, email: CSedtha@fhi360.org


## កំណត់សម្គាល់សម្រាប់ការនិពន្ធ

- **អង្គការ ហេឡែន ខេលល័រ អន្តរជាតិ**គឺជាអង្គការមួយបម្រើវិស័យសុខភាពសកលដែលផ្តោតសំខាន់លើការលុបបំបាត់ភាពពិការភ្នែក បញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់និងភាពក្រីក្រ។ ដោយមានលោកស្រី ហេឡែន ខេលល័រ ជាសហស្ថាបនិក - តាមរយៈមត្តទ្វេសក៍ប្រកបដោយគតិបណ្ឌិត សុទិដ្ឋិនិយម និងជំនឿលើសក្តានុពលរបស់ មនុស្សគ្រប់រូប - អង្គការនេះបានផ្តល់នូវដំណោះស្រាយសុខភាពដែលអាចធ្វើឱ្យមានការផ្លាស់ប្តូរ វិជ្ជមានលើការរស់នៅរបស់គ្រួសារងាយរងគ្រោះនៅតំបន់ផ្សេងៗជុំវិញពិភពលោកដែលមានតម្រូវការច្រើននិងមានលទ្ធភាពតិច តួចក្នុងការទទួលបាននូវការគាំទ្រនិងថែទាំ។ នៅសហរដ្ឋអាមេរិក ទ្វីបអាហ្វ្រិក និងទ្វីបអាស៊ី គម្រោងអន្តរាគមន៍ ផ្អែកលើភស្តុតាងវិទ្យាសាស្ត្រនានា របស់អង្គការ ហេឡែន ខេលល័រ បានផ្តល់អំណាចដល់បុគ្គល គ្រប់រូបក្នុងសង្គមក្នុងការបង្កើតឱកាសនៅក្នុងជីវិតផ្ទាល់ខ្លួននិងបង្កើតការផ្លាស់ប្តូរវិជ្ជមានក្នុងរយៈពេលយូរអង្វែង។ លោកស្រី ហេឡែន ខេលល័រ បានយកឈ្នះឧបសគ្គយ៉ាងធំធេងទៅលើផ្នែកសុខភាពនិងសុខុមាលភាព របស់គាត់ផ្ទាល់ ហើយគាត់បានជួយមនុស្សរាប់លាននាក់នៅជុំវិញពិភពលោក ឱ្យខិតខំតស៊ូព្យាយាមជំនះគ្រប់ឧបសគ្គដូចរូបគាត់ដែរ។ តាមរយៈមត្តទ្វេសក៍និងកេរដំណែលដ៏អស្ចារ្យរបស់គាត់ អង្គការហេឡែន ខេលល័រ បានចាប់ដៃគូនិងចូលរួមជាមួយរដ្ឋាភិបាល អង្គការសង្គមស៊ីវិលដៃគូអភិវឌ្ឍន៍នានា និងសហគមន៍ដែលកំពុង ប្រយុទ្ធប្រឆាំង និងកាត់ផ្តាច់វដ្តនៃភាពក្រីក្រដើម្បីសុខភាពនិងសុខុមាលភាពរបស់បុគ្គលគ្រប់រូបក្នុងរយៈពេលដ៏យូរអង្វែងមួយ។
  សម្រាប់ព័ត៌មានបន្ថែមទាក់ទងអង្គការហេឡែនខេលល័រ សូមចូលទៅកាន់៖ Helen Keller International - Continuing Her Work (hki.org)
- **អង្គការទស្សនៈពិភពលោកអន្តរជាតិ** ជាអង្គការគ្រីស្ទបរិស័ទដែលផ្តល់ជំនួយ អភិវឌ្ឍ និងតស៊ូមតិ ដែលប្តេជ្ញាធ្វើការជួយដល់កុមារ គ្រួសារ និងសហគមន៍ ឱ្យចាកចេញពីភាពក្រីក្រ និងអយុត្តិធម៌។ អង្គការទស្សនៈពិភពលោក ធ្វើការដើម្បីប្រជាជនទាំងអស់ដោយមិនគិតពីសាសនា ជាតិសាសន៍ ជាតិពន្ធុ ឬភេទឡើង។ អង្គការទស្សនៈពិភពលោក ចាប់ផ្តើមធ្វើការនៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៧០។ ដោយធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងនានារបស់រដ្ឋាភិបាល ដៃគូរមូលដ្ឋាន និងក្រុមសហគមន៍ យើងសហការជាមួយសហគមន៍ ក្នុងការធ្វើឱ្យប្រសើរឡើងនូវជីវិតរបស់កុមារកម្ពុជា ជាពិសេសកុមារងាយរងគ្រោះបំផុត តាមរយៈកម្មវិធីសំខាន់ៗ៣ រួមមានអាហារូបត្ថម្ភ ការអប់រំ និងការការពារនិងការចូលរួមរបស់កុមារ។ អង្គការទស្សនៈពិភពលោក កំពុងអនុវត្តន៍គម្រោងនានារបស់ខ្លួននៅបណ្តាខេត្តចំនួន១៥ និងរាជធានីភ្នំពេញ។ អង្គការទស្សនៈពិភពលោក កំពុងអនុវត្តកម្មវិធីតំបន់រយៈពេលវែងក្នុងបណ្តាខេត្តចំនួន៩ (បន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ កណ្តាល កំពង់ធំ ព្រះវិហារ សៀមរាប និងខេត្តតាកែវ) និងរាជធានីភ្នំពេញ។ គម្រោងតាមរយៈជំនួយ បានពង្រីកដល់ខេត្តកែប កំពង់ចាម ព្រះសីហនុ ព្រៃវែង ពោធិ៍សាត់ និងខេត្តស្វាយរៀង។
  សម្រាប់ព័ត៌មានបន្ថែមទាក់ទងនឹងអង្គការទស្សនៈពិភពលោក សូមចូលទៅកាន់៖ https://www.wvi.org/publications/cambodia

- Alive & Thrive (A&T) ជាគំនិតផ្តួចផ្តើមថ្នាក់អន្តរជាតិមួយដែលផ្តោតសំខាន់លើអាហារូបត្ថម្ភ ក្នុងគោលបំណងដើម្បីគាំពារជីវិត បង្ការជំងឺនានា និងដើម្បីធានាថាទាំងម្តាយ និងទារកអាចលូតលាស់និងមានសុខភាពល្អ។ ចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៤ A&T បានបង្ហាញអោយឃើញថាការអភិវឌ្ឍន៍ និងការលើកកំពស់ កម្មវិធីចិញ្ចឹមទារក និងកុមារតូច (IYCF) អាចធ្វើទៅបានយ៉ាងឆាប់រហ័ស នៅក្នុងបរិបទមួយដែលចម្រុះខ្លាំង ដូចជានៅក្នុងប្រទេសអេត្យូពី ប្រទេសបង់ក្លាដេស និងប្រទេសវៀតណាម។ នៅក្នុងឆ្នាំ ២០១៤ A&T បានចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសដ៏ទៃទៀតដូចជា បូគីណាហ្វាសូ ឥណ្ឌា នីហ្សេរីយ៉ា និងប្រទេសនានាក្នុងតំបន់អាស៊ីអាគ្នេយ៍ ក្នុងគោលបំនងពង្រីកវិសាលភាព

ការងារ ដោយរួមបញ្ចូល កម្មវិធីអាហារូបត្ថម្ភសម្រាប់មាតា និងកុមារវ័យជំទង់ និងការប្រើប្រាស់កម្មវិធីគាំពារសង្គមធ្វើជាយន្តការក្នុងការអនុវត្ត កម្មវិធីអាហារូបត្ថម្ភមាតា ទារក និងកុមារតូច (MIYCN)។ បច្ចុប្បន្ន Alive & Thrive កំពុងប្រើប្រាស់បណ្តាញការងារ និងមូលដ្ឋានចំណេះដឹងដ៏រឹងមាំរបស់ខ្លួន ដើម្បីពង្រឹងប្រព័ន្ធនិងការកសាងសមត្ថភាព នៅក្នុងប្រទេសនានាខាងលើ និងនៅប្រទេសដ៏ទៃទៀតនៅទូទាំងទ្វីបអាហ្វ្រិកនិងអាស៊ី ហើយបន្តផ្សព្វផ្សាយចែករំលែកនវានុវត្តន៍ថ្មីៗ ឧបករណ៍និងមេរៀននានា ទូទាំងពិភពលោក។ Alive & Thrive ជាកម្មវិធីនៅក្រោមអង្គការ FHI 360 ដោយទទួលបានជំនួយពីមូលនិធិ Bill & Melinda Gates ជំនួយថវិការពីរដ្ឋាភិបាលអៀរឡង់ និងម្ចាស់ជំនួយផ្សេងៗទៀត។

ព័ត៌មានបន្ថែមសម្រាប់គម្រោងនេះសូមចូលទៅកាន់៖ https://www.aliveandthrive.org/en